**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ សហចៅក្រមស៊ើបអង្កេត

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០១៦

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 09-Jun-2016, 11:02
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើរបស់ មាស មុត សុំឲ្យធ្វើចំណាត់ប្រភេទឯកសារឡើងវិញជាឯកសារសាធារណៈ ចំពោះសំណើរបស់គាត់សុំឲ្យយកសម្ភារៈឯកសាររបស់អង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា សេចក្តីជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីការព្យាយាមមិនបានសម្រេចដើម្បីទទួលបានឯកសារបណ្ណសារសម្ងាត់បំផុតរបស់អង្គការសហប្រជាជាតិ លិខិតរបស់អង្គការសហប្រជាជាតិផ្ញើជូនសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និង រាល់ខ្សែសម្ព័ន្ធភ្ជាប់មកជាមួយទាំងអស់**

**និង**

**សំណើសុំដាក់ក្នុងសំណុំរឿង និង ដាក់ជាសាធារណៈនូវលិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិផ្ញើជូនអង្គការសហប្រជាជាតិ ស្នើសុំឯកសារបណ្ណសារសម្ងាត់បំផុត**

---

**ដាក់ដោយ៖**

**សហមេធាវី៖**

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន៖**

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្ដី") អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. ("វិធាន") តាមរយៈនេះ ស្នើសុំ៖ **ក.** ឲ្យធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈចំពោះ *សំណើរបស់ មាស មុត សុំឲ្យយក និង ដាក់ទៅក្នុងសំណុំរឿងនូវសម្ភារៈឯកសាររបស់អង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការចរចាបង្កើត អ.វ.ត.ក.* (ឯកសារ **D170**) និង ឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងសំណើនេះ (ឯកសារ **D170.2**) **ខ.** ឲ្យដាក់ក្នុងសំណុំរឿង និង ធ្វើចំណាត់ប្រភេទជាឯកសារសាធារណៈ នូវលិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិផ្ញើជូនអង្គការសហប្រជាជាតិ ("អ.ស.ប.") ស្នើសុំឯកសារបណ្ណសារសម្ងាត់បំផុត **គ.** ឲ្យធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈ ចំពោះចម្លើយរបស់អង្គការសហប្រជាជាតិតបទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ឯកសារ **D181/1.1**) និង ឯកសារភ្ជាប់មកជាមួយនឹងចម្លើយនេះ (ឯកសារ **D181/1.2**, **D181/1.3** និង ឯកសារ **D181/1.4**) និង **ឃ.** ឲ្យធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈចំពោះ *សេចក្តីជូនដំណឹងអំពីការព្យាយាមមិនបានសម្រេច ដើម្បីទទួលបានឯកសារបណ្ណសារសម្ងាត់បំផុតរបស់អង្គការសហប្រជាជាតិ* របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ឯកសារ **D181/1**)។ ឯកសារទាំងនេះត្រូវបានហៅរួមគ្នានៅក្នុងសំណើនេះថា ឯកសារ។ សំណើនេះត្រូវបានធ្វើឡើងជាចាំបាច់ ដើម្បីផលប្រយោជន៍តម្លាភាព និង យុត្តិធម៌។ សាធារណជនមានផលប្រយោជន៍ក្នុងការទទួលបានព័ត៌មានអំពីកិច្ចដំណើរការនីតិវិធី កិច្ចខិតខំប្រឹងប្រែងស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងរឿងក្តី ០០៣ និង ការគ្មានឆន្ទៈរបស់ អ.ស.ប. ក្នុងការអនុវត្តតាមកិច្ចខិតខំប្រឹងប្រែងស៊ើបអង្កេតដែលបានលើកឡើងនេះ។ គ្មានឯកសារណាមួយក្នុងចំណោមឯកសារទាំងនេះ មានព័ត៌មានសម្ងាត់ ឬ ព័ត៌មានរសើប ដែលមិនអាចកោសលុបបាននោះឡើយ។ ព័ត៌មានដែលមិនទាក់ទងជាពិសេស ទៅនឹងអង្គហេតុដែលកំពុងស្ថិតនៅក្រោមការស៊ើបអង្កេតតាមផ្លូវតុលាការ មិនចាំបាច់ និង មិនត្រូវបន្តរក្សាទុកជាព័ត៌មានសម្ងាត់ឡើយ។ មេធាវីការពារក្តីស្នើសុំដាក់សំណើនេះជាភាសាអង់គ្លេសសិន ដោយដាក់ការបកប្រែជាភាសាខ្មែរតាមក្រោយ ព្រោះថាការបកប្រែជាភាសាខ្មែរមិនអាចនឹងបញ្ចប់ទៅតាមពេលវេលាកំណត់[1]។

---

[1] អង្គភាពបកប្រែភាសា បានបង្ហាញថា សំណើនេះមិនអាចត្រូវបានបកប្រែជាភាសាខ្មែរទេ រហូតដល់ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១៦។ សារអេឡិចត្រូនិចពីអង្គភាពបកប្រែភាសាជូនមេធាវីការពារក្តី "ឆ្លើយតប៖ លេខ ERNs 01239929-01239939" ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០១៦។

## I. ច្បាប់ជាធរមាន

១. មាត្រា ៣.១២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក. ("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ") ចែងថា៖

> អំឡុងពេលស៊ើបសួររបស់តុលាការ ភាគីដែលដាក់ឯកសារអាចស្នើសុំឲ្យដាក់ចំណាត់ប្រភេទឯកសារជាឯកសារ "សាធារណៈ" "សម្ងាត់" ឬ "សម្ងាត់បំផុត" ដោយអនុលោមតាមបទប្បញ្ញត្តិនៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទឯកសារ និង ការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង។ តាមករណីសមស្រប ទាល់តែមានការចេញដីកាដំណោះស្រាយ និង សេចក្តីសម្រេចប្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ ទើបសហចៅក្រមស៊ើបអង្កេត និង អង្គបុរេជំនុំជម្រះត្រូវពិនិត្យពិចារណាថា តើចំណាត់ប្រភេទឯកសារដែលបានស្នើសុំនោះមានលក្ខណៈសមស្របដែរឬទេ ហើយបើសិនជាមិនសមស្របទេ ត្រូវធ្វើសេចក្តីសម្រេចថា តើចំណាត់ប្រភេទអ្វីទៅទើបសមស្រប។ សេចក្តីសម្រេចបែបនេះ ត្រូវមានអនុភាពអនុវត្តក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីបន្តបន្ទាប់ ដែលត្រូវស្របនឹងមាត្រា ៣.១៤។

២. មាត្រា ៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ចែងថា៖

> តម្រូវតាមផលប្រយោជន៍យុត្តិធម៌ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះដែលគ្រប់គ្រងសំណុំរឿង អាចដាក់ចំណាត់ប្រភេទឯកសារជាថ្មីក្នុងសំណុំរឿង។ ភាគីជាប់ពាក់ព័ន្ធនឹងត្រូវផ្តល់ឱកាសឲ្យបានដឹង និង ធ្វើការឆ្លើយតប មុនមានការធ្វើសេចក្តីសម្រេចបែបនេះ ឬ ក្នុងអំឡុងពេលដាក់ចំណាត់ប្រភេទជាថ្មីបណ្តោះអាសន្ន ដែលជាការចាំបាច់ក្នុងការការពារព័ត៌មានដែលអាចជាព័ត៌មានសម្ងាត់ ឬ សម្ងាត់បំផុត។ នៅក្នុងករណីនេះ ភាគីពាក់ព័ន្ធនឹងសំណុំរឿងត្រូវបានជូនដំណឹងអំពីការដាក់ចំណាត់ប្រភេទជាថ្មីបណ្តោះអាសន្ន និង អំពីសេចក្តីសម្រេចដាក់ចំណាត់ប្រភេទជាថ្មី។

៣. មាត្រា ១.២ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និង ការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង ("សេចក្តីណែនាំស្តីពីចំណាត់ប្រភេទឯកសារ") ចែងថា៖

> គោលការណ៍ដែលនាំឲ្យមានសេចក្តីណែនាំអនុវត្តនេះ គឺជាតម្រូវការទាមទារឲ្យមាន

តុល្យភាពរវាងការសម្ងាត់នៃការស៊ើបអង្កេតរបស់តុលាការ និង ផ្នែកផ្សេងៗទៀតនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ ដែលមិនបើកចំហដល់សាធារណជន តម្រូវការដើម្បីធានាដល់តម្លាភាពនៃកិច្ចដំណើរការនីតិវិធីសាធារណៈ និង សម្រាប់គោលបំណងនៃការអប់រំ និង កេរដំណែល។

៤. មាត្រា ៩.២ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទឯកសារ ចែងថា៖

អត្ថបទឯកសារសាធារណៈនៃឯកសារសម្ងាត់ ឬ សម្ងាត់បំផុត អាចត្រូវគេរៀបចំឡើងដើម្បីដាក់ក្នុងផ្នែកសាធារណៈនៃសំណុំរឿង តាមការណែនាំរបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ តាមករណីសមស្រប។ អត្ថបទឯកសារសាធារណៈថ្មីអាចនឹងត្រូវរៀបចំតាមរយៈ៖

ក. បង្កើតច្បាប់ចម្លងពីឯកសារច្បាប់ដើម។

ខ. កាត់ចេញពីផ្នែកនៃច្បាប់ចម្លងព័ត៌មានសម្ងាត់ និង សម្ងាត់បំផុតទាំងអស់ដែលអាចធ្វើបាន។ និង

គ. បញ្ជូនអត្ថបទដែលបន្ទាប់ពីកាត់ចេញមកនោះ ទៅសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ដើម្បីពិនិត្យឡើងវិញ និង សម្រេច មុននឹងដាក់ឯកសារទាំងនោះចូលទៅក្នុងផ្នែកសាធារណៈនៃសំណុំរឿង។

អត្ថបទឯកសារសម្ងាត់នៃឯកសារសម្ងាត់បំផុត អាចត្រូវគេរៀបចំឡើង តាមរបៀបប្រហាក់ប្រហែលគ្នានេះដែរ។

៥. មាត្រា ៩.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទឯកសារ ចែងថា៖

បើសិនអត្ថបទឯកសារសាធារណៈនៃឯកសារសម្ងាត់ ឬ សម្ងាត់បំផុត ត្រូវបានរៀបចំឡើងតាមសំណើភាគីមួយ ការកាត់ចេញផ្នែកណាខ្លះណាមួយត្រូវធ្វើឡើងដោយភាគីស្នើសុំ និង ដាក់ស្នើសុំការអនុញ្ញាត ដោយអនុលោមតាម មាត្រា ៩.២ (គ)។

## II. សាវតារ

៦. នៅថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០០៩ ការិយាល័យសហព្រះរាជអាជ្ញាបានផ្តួចផ្តើមឲ្យមានកិច្ចស៊ើបសួរលើរឿងក្តី ០០៣ ដោយផ្អែកលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ២ ទាក់ទងទៅនឹងកងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៨[2]។

៧. នៅថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១៥ មេធាវីការពារក្តីបានដាក់ឯកសារ **D170** ស្នើទៅសហចៅក្រមស៊ើបអង្កេត ឲ្យយកសម្ភារៈឯកសាររបស់ អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការចរចាបង្កើត អ.វ.ត.ក. និង សេចក្តីព្រាងនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និង ដាក់សម្ភារៈឯកសារនេះទៅក្នុងសំណុំរឿង។ មេធាវីការពារក្តីបានលើកឡើងថា អង្គជំនុំជម្រះតុលាការកំពូលបានភ័ន្តច្រឡំក្នុងការសម្រេចថា ពាក្យ *មេដឹកនាំជាន់ខ្ពស់* និង *អ្នកទទួលខុសត្រូវខ្ពស់បំផុត* មិនមែនជាការដាក់កម្រិតផ្នែកយុត្តាធិការលើ អ.វ.ត.ក. ប៉ុន្តែ ជាកត្តាឆន្ទានុសិទ្ធិទាក់ទងនឹងសេចក្តីសម្រេចលើគោលនយោបាយនៃការចោទប្រកាន់ និង ការស៊ើបសួរ។ មេធាវីការពារក្តីបានលើកឡើងថា ការយកសម្ភារៈឯកសាររបស់ អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា គឺជាការចាំបាច់ ដើម្បីជំទាស់តវ៉ានឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល និង ជួយដល់សហចៅក្រមស៊ើបអង្កេត អង្គជំនុំជម្រះ និង ភាគីទាំងអស់ ក្នុងការកំណត់ពីចេតនារបស់អ្នករៀបចំសេចក្តីព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និង អត្ថន័យនៃពាក្យ *មេដឹកនាំជាន់ខ្ពស់* និង *អ្នកទទួលខុសត្រូវខ្ពស់បំផុត*។ មេធាវីការពារក្តីបានភ្ជាប់ឧបសម្ព័ន្ធឯកសារ **D170.2** ដែលរៀបរាប់ពីសម្ភារៈឯកសារពាក់ព័ន្ធសំខាន់ៗរបស់ អ.ស.ប. ក្នុងនោះឯកសារមួយចំនួនត្រូវបានធ្វើចំណាត់ប្រភេទជាឯកសារសម្ងាត់បំផុត និង ឯកសារខ្លះទៀតមិនមែនជាឯកសារសម្ងាត់នោះទេ។

៨. នៅថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាសម្រេចរួមលើសំណើរបស់ មាស មុត ស្តីពីយុត្តាធិការបុគ្គល[3]។ នៅក្នុងដីកាសម្រេចរបស់គាត់ *ក្នុងចំណោមនោះ* សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានអនុញ្ញាតតាមឯកសារ **D170** ដោយសម្រេចថា ការពិនិត្យមើលលើ *កំណត់ហេតុនៃកិច្ចចរចា* (travaux préparatoires) ជាមធ្យោបាយបន្ថែម

---

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ២ របស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងកងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។

[3] ដីកាសម្រេចរួមលើសំណើរបស់ មាស មុត ស្តីពីយុត្តាធិការបុគ្គល ចុះថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D181។

សម្រាប់ធ្វើការបកស្រាយចេតនារបស់អ្នករៀបចំសេចក្តីព្រាង នៅពេលចរចាបង្កើត អ.វ.ត.ក. "ច្បាស់ណាស់ អាចជួយ ស.ច.ស. បកស្រាយពាក្យពេចន៍ទាំងនោះ [*មេដឹកនាំជាន់ខ្ពស់* និង *អ្នកទទួលខុសត្រូវខ្ពស់បំផុត*]"[4]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយល់ស្របថា ដើម្បីបញ្ជាក់ពីចេតនារបស់អ្នករៀបចំសេចក្តីព្រាង វាជាការចាំបាច់ដែលត្រូវពិចារណាលើប្រវត្តិទាំងស្រុងនៃកិច្ចចរចា ជាជាងឯកសារដែលត្រូវបានសម្រិតសម្រាំង[5]។ គាត់បានថ្លែងថា គាត់នឹងខិតខំប្រឹងប្រែង ជាពិសេស ដើម្បីទទួលបានឯកសារបណ្ណសារសម្ងាត់បំផុតទាំងនោះ ដែលមាននៅក្នុងឯកសារ **D170.2** ហើយដាក់ឯកសារទាំងនោះឲ្យមានសម្រាប់ភាគីទាំងអស់នៅក្នុងរឿងក្តី ០០៣[6]។

៩. នៅថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីជូនដំណឹងឯកសារ **D181/1**។ គាត់បានបង្ហាញថា គាត់បានសរសេរលិខិតទៅ អ.ស.ប. ដើម្បីស្នើសុំឯកសារសម្ងាត់បំផុតដែលមានរៀបរាប់ក្នុងឯកសារ **D170.2**[7]។ អគ្គលេខាធិការរងនៃ អ.ស.ប. ទទួលបន្ទុកកិច្ចការច្បាប់ បានឆ្លើយតបថា ឯកសារបណ្ណសារសម្ងាត់បំផុតរបស់ អ.ស.ប. មិនអាចបង្ហាញជូនបានទេ ពីព្រោះឯកសារទាំងនោះត្រូវបានចាត់ទុកថាជាឯកសាររសើប អនុលោមតាមសេចក្តីប្រកាស អ.ស.ប. ស្តីពីចំណាត់ថ្នាក់ និង ការចាត់ចែងព័ត៌មាន[8]។ អគ្គលេខាធិការរងរូបនេះបានផ្តល់ឲ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិនូវឯកសារមួយចំនួន ដែលអាចដាក់បង្ហាញបាន៖ សេចក្តីសម្រេចរបស់មហាសន្និបាត អ.ស.ប. របាយការណ៍អំពីប្រទេសកម្ពុជារបស់អគ្គលេខាធិការ អ.ស.ប. និង ប្រតិចារឹក និង អត្ថបទសារព័ត៌មានដែលទាក់ទងនឹងអំឡុងពេលនៃកិច្ចចរចា[9]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានថ្លែងថា ដោយសារគ្មានការអនុញ្ញាតពី អ.ស.ប.គាត់មិនអាចស្នើសុំឲ្យផ្តល់ឯកសារសម្ងាត់បំផុតពីបណ្ណសារដ្ឋានរបស់ អ.ស.ប. បានឡើយ ប៉ុន្តែគាត់នឹង

---

[4] *ដូចខាងលើ* កថាខណ្ឌ ៣២។

[5] *ដូចខាងលើ* កថាខណ្ឌ ៣៣។

[6] *ដូចខាងលើ*។

[7] សេចក្តីជូនដំណឹងអំពីការព្យាយាមមិនបានសម្រេច ដើម្បីទទួលបានឯកសារបណ្ណសារសម្ងាត់បំផុតរបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D181/1 កថាខណ្ឌ ៥។

[8] *ដូចខាងលើ* កថាខណ្ឌ ៥។

[9] *ដូចខាងលើ*។

ចាត់វិធានការចាំបាច់ដើម្បីទទួលបានឯកសារដែលចាត់ជាសាធារណៈ រៀបរាប់នៅក្នុងឯកសារ **D170.2**[10]។

## III. ឧឡឹករណ៍

១០. កិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក. ត្រូវតែមានតម្លាភាព[11]។ ខណៈដែលចាំបាច់ត្រូវរក្សាការសម្ងាត់នៅក្នុងកិច្ចស៊ើបសួរ[12] ភាពចាំបាច់នេះត្រូវតែមានតុល្យភាពជាមួយនឹងសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានតម្លាភាព[13] ផលប្រយោជន៍យុត្តិធម៌[14] និង ភាពចាំបាច់ក្នុងការផ្តល់ព័ត៌មាន និង ការអប់រំដល់សាធារណជនអំពីកិច្ចដំណើរការនីតិវិធី[15]។ មេធាវីការពារក្តីបានលើកទឡ្ហីករណ៍ម្តងហើយម្តងទៀតថា ឯកសារសំណុំរឿងដែលមិនពិភាក្សាអំពីអង្គសេចក្តីនៃកិច្ចស៊ើបអង្កេតក្នុងរឿងក្តី ០០៣ គួរត្រូវបានធ្វើចំណាត់ប្រភេទជាឯកសារសាធារណៈ ដើម្បីលើកកម្ពស់តម្លាភាព និង

---

[10] *ដូចខាងលើ* កថាខណ្ឌ ៦។

[11] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ដែលកែប្រែដោយព្រះរាជក្រម ចុះថ្ងៃទី ៨ ខែមីនា ១៩៩៩ ដែលប្រកាសឲ្យប្រើវិសោធនកម្ម មាត្រា ១១ មាត្រា ១២ មាត្រា ១៣ មាត្រា ១៨ មាត្រា ២២ មាត្រា ២៤ មាត្រា ២៦ មាត្រា ២៨ មាត្រា ៣០ មាត្រា ៣៤ មាត្រា ៥១ មាត្រា ៩០ មាត្រា ៩១ មាត្រា ៩៣ និង មាត្រាផ្សេងៗទៀត ចាប់ពីជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តដោយសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ៤ ខែមីនា ឆ្នាំ ១៩៩៩។ មាត្រា ១៣(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។ មាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។ វិធាន ២១(១) នៃវិធានផ្ទៃក្នុង។ មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដែលបានអនុម័ត និង បើកឲ្យចុះហត្ថលេខា ផ្តល់សច្ចាប័ន និង ចូលជាសមាជិក ដោយសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ 2200A (XXI) ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦ និង ចូលជាធរមាន នៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៧៦ អនុលោមតាមមាត្រា ៤៩។

[12] *សូមមើល* វិធាន ៥៦(១) នៃវិធានផ្ទៃក្នុង។

[13] ដីកាសម្រេចលើសំណើរបស់ មាស មុត សុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញជាឯកសារសាធារណៈ ដោយមានឧបសម្ព័ន្ធ ក និង ខ ជាឯកសារសាធារណៈ និង ឧបសម្ព័ន្ធ គ ជាឯកសារសម្ងាត់ ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D129/1 កថាខណ្ឌ ១១។

[14] *សូមមើល* មាត្រា ៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។

[15] *សូមមើល* មាត្រា ១.២ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទឯកសារ។

ផ្តល់ព័ត៌មានដល់សាធារណជនអំពីកិច្ចដំណើរការនីតិវិធី[16]។ មេធាវីការពារក្តីលើកឡើងជាថ្មីម្តងទៀតនៅក្នុងសំណើនេះ។ គ្មានតេស្តតុល្យភាពសម្រាប់បំពេញឡើយនៅទីនេះ។ សិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានតម្លាភាពនៃកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ ផលប្រយោជន៍យុត្តិធម៌ និង តម្រូវការរបស់សាធារណជន តម្រូវឱ្យដាក់ឯកសារទាំងនេះជាសាធារណៈ។

១១. មិនមានសំអាងហេតុចាំបាច់ណាមួយ ដែលតម្រូវឱ្យរក្សាទុកឯកសារទាំងនេះពីសាធារណជនឡើយ។ បញ្ហានៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ទៅលើលោក មាស មុត គឺជាបញ្ហាផ្លូវច្បាប់ដែលត្រូវដោះស្រាយ។ បញ្ហានេះគឺជាចំណុចស្នូលនៃរឿងក្តីប្រឆាំងនឹងគាត់។ ពុំមានការពិភាក្សាលើអង្គហេតុណាមួយដែលចាំបាច់ សម្រាប់កំណត់ពីចេតនារបស់ស្ថាបនិក អ.វ.ត.ក. ទាក់ទងនឹងលក្ខណៈយុត្តាធិការ ឬ ឆន្ទានុសិទ្ធិនៃយុត្តាធិការបុគ្គលឡើយ។ ជាទូទៅ ឯកសារនេះទាក់ទងនឹងបញ្ហាច្បាប់ ដែលជាប្រធានបទនៃការជជែកតវ៉ាជាសាធារណៈ និង ពិភាក្សាយ៉ាងទូលំទូលាយ[17]។

---

[16] *សូមមើល ឧទាហរណ៍* សំណើរបស់ មាស មុត សុំឱ្យធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈ ចំពោះសំណើរបស់គាត់ សុំដាក់ប្រតិចារឹកទាំងមូលនៃកំណត់ហេតុស្តាប់ចម្លើយទាំងអស់បញ្ចូលទៅក្នុងសំណុំរឿង និង ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើនេះ ចុះថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D87/2/1.8/2។ សំណើរបស់ មាស មុត សុំឱ្យធ្វើចំណាត់ប្រភេទឯកសារឡើងវិញជាឯកសារសាធារណៈ ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ ២០១៥ ឯកសារ D129។ សំណើរបស់ មាស មុត សុំឱ្យសហចៅក្រមស៊ើបអង្កេត Harmon ពិចារណាសាជាថ្មីទៅលើដីកាសម្រេចរបស់គាត់លើសំណើរបស់ មាស មុត សុំឱ្យធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ជាឯកសារសាធារណៈ ដោយមានឧបសម្ព័ន្ធជាឯកសារសម្ងាត់ ចុះថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D129/2។ សំណើរបស់ មាស មុត សុំឱ្យធ្វើចំណាត់ប្រភេទឯកសារឡើងវិញជាឯកសារសាធារណៈចំពោះដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ មាស មុត សុំឱ្យសហចៅក្រមស៊ើបអង្កេតបញ្ជាក់បំភ្លឺថា តើមេធាវីការពារក្តីអាចទាក់ទងជាមួយបុគ្គលទាំងឡាយ រួមទាំងសាក្សី [redacted] បានឬយ៉ាងណា និង សំណើរបស់ មាស មុត សុំឱ្យសហចៅក្រមស៊ើបអង្កេតបញ្ជាក់បំភ្លឺថា តើមេធាវីការពារក្តីអាចទាក់ទងជាមួយបុគ្គលទាំងឡាយ រួមទាំងសាក្សី [redacted] បានឬយ៉ាងណា ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D173/2។ សំណើរបស់ មាស មុត សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញជាឯកសារសាធារណៈចំពោះឯកសារ D87/2/1.6 និង ឯកសារ D87/2/1.6/1 ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៦ ឯកសារ D180។

[17] *សូមមើល ឧទាហរណ៍ រឿងក្តី កាំងហ្កេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ៦២ ដល់កថាខណ្ឌ ៧៩។ សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ឯកសារ D13។ [កោសលុប] ដីកាសម្រេចលើយុត្តាធិការបុគ្គល និង គោលនយោបាយកិច្ចស៊ើបសួរពាក់ព័ន្ធនឹងជនសង្ស័យ ចុះថ្ងៃទី ២ ខែឧសភា ឆ្នាំ ២០១២។ Thomas Miller *ចៅក្រមតុលាការខ្មែរក្រហមជជែកអំពីភាពចម្រូងចម្រាសគ្នាក្នុងតុលាការ* (KRT Judge Talks Court Controversies) សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០១១។ Sean Morrison *ភាសាវិសាមញ្ញក្នុងតុលាការកម្ពុជា៖ ការបកស្រាយភាសាមានកម្រិត និង យុត្តាធិការ*

ខណៈដែលអាចមានភាពចាំបាច់ក្នុងការរក្សាការសម្ងាត់ចំពោះផ្នែកខ្លះនៃកិច្ចស៊ើបសួរ ដូចជា ផ្នែកទាក់ទងនឹងសាក្សី ឬ អង្គហេតុជាក់លាក់ ផ្នែកទាំងនេះមិនមែនជាបញ្ហាឡើយនៅទីនេះ។ ឯកសារទាំងនេះមិនមានការទាក់ទងដោយផ្ទាល់ទៅនឹងអង្គហេតុ ដែលកំពុងស្ថិតក្រោមការស៊ើបអង្កេតក្នុងរឿងក្តី ០០៣ ឡើយ។ ការធ្វើចំណាត់ប្រភេទនៃឯកសារទាំងនេះជាឯកសារសម្ងាត់ដោយស្វ័យប្រវត្តិ ជំរុញឲ្យមានវប្បធម៌មួយ ដែលតម្លាភាពជាករណីលើកលែងយ៉ាងកម្រ។ ជាការគួរឲ្យសោកស្តាយនៅក្នុងវប្បធម៌បែបនេះ កាំរស្មីនៃពន្លឺថ្ងៃតែមួយចំនួនតូចប៉ុណ្ណោះ ដែលអាចទម្លុះចូលរបាំងនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបាន[18]។

១២. ដូចដែលអង្គការយុត្តិធម៌សង្គមសេរី (“អង្គការ OSJI”) បានកត់សម្គាល់ទាក់ទងនឹង អ.វ.ត.ក.៖ “នៅពេលដែលអវត្តមាននៃការបង្ហាញឲ្យឃើញពីភាពចាំបាច់នៃការរក្សាការសម្ងាត់ តាមស្ថានភាពជាក់ស្តែង វិធានដែលគាំទ្រដល់តម្លាភាព គួរតែត្រូវបានអនុវត្ត ដើម្បីអាចឲ្យសាធារណជនសង្កេតមើលការងាររបស់តុលាការ”[19]។ ឧទាហរណ៍មួយដែលអង្គការ OSJI បានដកស្រង់ដើម្បីបង្ហាញពីការប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពនៃតម្លាភាព គឺដីការបស់ Lemonde អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងរឿងក្តី ០០២ ដែលសម្រេចបង្ហាញជាសាធារណៈនូវដីកាកោះហៅមន្ត្រីរដ្ឋាភិបាលចំនួនប្រាំមួយរូបពីគណបក្សប្រជាជនកម្ពុជា[20]។ ដីកាកោះទាំងនេះទាក់ទងនឹងអង្គហេតុ

---

*បុគ្គលនៃតុលាការកម្ពុជា* (Extraordinary Language in the Courts of Cambodia: Interpreting the Limiting Language and Personal Jurisdiction of the Cambodian Tribunal) 37 CAP. U. L. REV. ៥៨៣, ៥៩៩ (ឆ្នាំ ២០០៩)។ Steve Heder *ការពិនិត្យឡើងវិញនៃកិច្ចចរចាដែលនាំដល់ការបង្កើតឲ្យមានយុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* (A Review of the Nagotiaions Leading to the Establishment of the Personal Jurisdiction of the Extraordinatry Chambers in the Courts of Cambodia) ចុះថ្ងៃទី ១ ខែសីហា ឆ្នាំ ២០១១។

[18] ដូចដែលលោកចៅក្រម Louis D. Brandeis នៃតុលាការកំពូលរបស់សហរដ្ឋអាមេរិក បានកត់សម្គាល់យ៉ាងសមស្របថា៖ “ពន្លឺថ្ងៃត្រូវបានគេនិយាយថាមានប្រសិទ្ធភាពបំផុតក្នុងការកម្ចាត់សរីរាង្គគ្រោះថ្នាក់ ចំណែកឯពន្លឺអគ្គិសនីគឺជានគរបាលដែលល្អបំផុត” (Sunlight is said to be the best of disinfectants; electric light the most efficient ppoliceman.)។ Louis D. Brandeis *តើអ្វីដែលអាចធ្វើបានជាសាធារណៈ?* (What Publicity Can Do) HARPER'S WEEKLY ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩១៣។

[19] អង្គការយុត្តិធម៌សង្គមសេរី *ការជ្រៀតជ្រែកផ្នែកនយោបាយនៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* ខែកក្កដា ឆ្នាំ ២០១០ ទំព័រ ២៧។

[20] *ដូចខាងលើ*។ *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស. លិខិតរបស់សហចៅក្រមស៊ើបអង្កេតផ្ញើជូនសាក្សី ហេង សំរិន ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៩ ឯកសារ D136/3។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស. លិខិតរបស់សហចៅក្រមស៊ើប

ដែលកំពុងស៊ើបអង្កេតក្នុងរឿងក្តី ០០២។ ទោះជាយ៉ាងនេះក្តី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបង្ហាញឯកសារទាំងនេះជាសាធារណៈ។ នៅទីនេះ *គ្មាន* ឯកសារណាមួយក្នុងចំណោមឯកសារទាំងនេះ ទាក់ទងនឹងអង្គហេតុដែលកំពុងស៊ើបអង្កេតក្នុងរឿងក្តី ០០៣ ឡើយ ទោះជាយ៉ាងនេះក្តី ឯកសារទាំងនេះនៅតែចាត់ទុកជាឯកសារសម្ងាត់។

១៣. ដូចក្នុងរឿងក្តី ០០៣ នៅពេលដែលមានការព្រួយបារម្ភខ្លាំងជាសាធារណៈអំពីការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាល និង ភាពអសកម្មរបស់ អ.ស.ប.[21] សាធារណជនគួរទទួលបានព័ត៌មានអំពីកិច្ចខិតខំប្រឹងប្រែងរបស់មេធាវីការពារក្តី និង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការបញ្ជាក់បំភ្លឺលើបញ្ហាផ្លូវច្បាប់ ដែលជាផ្នែកសំខាន់ក្នុងរឿងក្តីនេះ។ ជាពិសេស និង សំខាន់នោះ នៅពេលពិចារណាលើការគាំទ្រ និង ការតស៊ូមតិរបស់ អ.ស.ប. ដែលតែងតែថ្លែងជាសាធារណៈ ដើម្បីឲ្យ

---

អង្កេតផ្ញើជូនសាក្សី ស៊ឹម កា ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៩ ឯកសារ A297។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស. លិខិតរបស់សហចៅក្រមស៊ើបអង្កេតផ្ញើជូនសាក្សី ហោ ណាំហុង ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ A299។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស. លិខិតរបស់សហចៅក្រមស៊ើបអង្កេតផ្ញើជូនសាក្សី គាត ឈន់ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៩ ឯកសារ A296។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស. លិខិតរបស់សហចៅក្រមស៊ើបអង្កេតផ្ញើជូនសាក្សី ជា ស៊ីម ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៩ D136/2។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស. លិខិតរបស់សហចៅក្រមស៊ើបអង្កេតផ្ញើជូនសាក្សី អ៊ុក ប៊ុនឈឿន ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៩ ឯកសារ A298។ *សូមមើលផងដែរ* ជាង សុផេង (Sopheng Cheang) *តុលាការខ្មែរក្រហមកោះហៅមន្ត្រីបក្សរដ្ឋាភិបាល* (Khmer Rouge Tribunal Summons Gov't Party Officials) ASSOCIATED PRESS ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០០៩ *អាចរកមើលបាននៅ* G:\Public Affairs\Daily Clippings International\Archives\2009។

[21] *សូមមើល ឧទាហរណ៍ ចៅក្រមតុលាការខ្មែរក្រហមជជែកអំពីភាពចម្រូងចម្រាសគ្នាក្នុងតុលាការ* សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០១១។ George Wright និង Kuon Narim *នគរបាលមិនអើពើនឹងដីកាចាប់ខ្លួន មាស មុត មួយផ្សេងទៀត* (Police Ignored Another Arrest Warrant of Meas Muth) សារព័ត៌មានខេមបូឌាដេលី ចុះថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០១៥។ Luke Hunt *ការលាឈប់ពីមុខតំណែងបង្កឲ្យមានភាពសង្ស័យបន្ថែមទៀតទៅលើតុលាការខ្មែរក្រហមក្នុងប្រទេសកម្ពុជា* (Resignation Casts Further Doubt Over Khmer Rouge Tribunal in Cambodia) THE DIPLOMAT ចុះថ្ងៃទី ៩ ខែកក្កដា ឆ្នាំ ២០១៥។

អ.វ.ត.ក. បន្តការស៊ើបអង្កេត និង ការចោទប្រកាន់នោះ[22] សាធារណជនត្រូវតែបានដឹងពីការដែល អ.ស.ប. មិនអនុវត្តតាមសំណើសុំកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ការលើកទឹកចិត្តឱ្យមានតម្លាភាពតាមរយៈការបង្ហាញឯកសារទាំងនេះជាសាធារណៈ ពង្រឹងបន្ថែមនីតិរដ្ឋ និង លើកកម្ពស់កេរដំណែល អ.វ.ត.ក. ជាតុលាការគំរូសម្រាប់ប្រទេសកម្ពុជា។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិគួរតែជ្រើសរើសតម្លាភាព ជាជាងភាពមិនច្បាស់លាស់។ សំណើជាក់លាក់ទាក់ទងនឹងឯកសារទាំងនេះមានដូចខាងក្រោម។

***<u>សំណើរបស់ មាស មុត សុំឱ្យយក និង ដាក់ក្នុងសំណុំរឿងនូវសម្ភារៈឯកសាររបស់អង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការចរចាបង្កើត អ.វ.ត.ក. (ឯកសារ D170 និង ឯកសារ D170.2)</u>***

១៤. ឯកសារ **D170** គឺជាសំណើរបស់លោក មាស មុត សុំសម្ភារៈឯកសាររបស់ អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជាអំពីកិច្ចចរចាបង្កើត អ.វ.ត.ក.។ មេធាវីការពារក្តីបានលើកឡើងថា សម្ភារៈឯកសារស្តីពីកិច្ចចរចារវាង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា គឺចាំបាច់សម្រាប់ជួយសហចៅក្រមស៊ើបអង្កេត អង្គជំនុំជម្រះ និង ភាគីទាំងអស់ ក្នុងការកំណត់ពីចេតនារបស់អ្នករៀបចំសេចក្តីព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ទាក់ទងនឹងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក.។ សំណើនេះសំដៅលើការប្តឹងផ្តល់កន្លងមកដែលត្រូវបានដឹង និង ផ្សព្វផ្សាយជាសាធារណៈ និង យោងឯកសារសម្ងាត់ចំនួនពីរពីរឿងក្តី ០០២ និង រឿងក្តី ០០៣។ អនុលោមតាមមាត្រា ៩.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទឯកសារ មេធាវីការពារក្តីបានភ្ជាប់មកជាមួយនូវសំណៅឯកសារ **D170** ដែលមានការកោសលុប ជាឧបសម្ព័ន្ធទៅនឹងសំណើនេះ។ ឯកសារ **D170.2** ដែលជាឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងឯកសារ **D170** យោងឯកសារដែលមេធាវីការពារ

---

[22] *សូមមើល ឧទាហរណ៍* សេចក្តីថ្លែងការណ៍រួមគ្នារវាងឧបនាយករដ្ឋមន្ត្រី សុខ អាន និង អ្នកជំនាញពិសេស អ.ស.ប. David Scheffer ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១៦។ សេចក្តីថ្លែងការណ៍រួមគ្នារវាងឧបនាយករដ្ឋមន្ត្រី សុខ អាន និង អ្នកជំនាញពិសេស អ.ស.ប. David Scheffer ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ២០១៦។ សេចក្តីថ្លែងការណ៍រួមស្តីពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០១៥។ សុន្ទរកថារបស់អ្នកជំនាញពិសេស អ.ស.ប. David Scheffer *តើមានអ្វីខ្លះដែល "វិសាមញ្ញ" អំពីយុត្តិធម៌អន្តរជាតិក្នុងប្រទេសកម្ពុជា?* (What Has Been 'Extraordinary' About International Justice in Cambodia?) ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥។ ឯកសារទាំងនេះ *អាចរកអានបាននៅ* http://www.unakrt-online.org/statements-articles។

ក្តីបានរកឃើញតាមប្រព័ន្ធអ៊ីនធើណែត ដូច្នេះ ព័ត៌មាននេះត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ ឯកសារទាំងនេះគួរតែត្រូវបានដាក់បង្ហាញជាសាធារណៈ។

១៥. គ្មានភាគី ឬ អង្គភាពនៃ អ.វ.ត.ក. នឹងរងព្យសនកម្មឡើយ ប្រសិនបើឯកសារ **D170** និង ឯកសារ **D170.2** ត្រូវបានធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈនោះ។ គ្មានឯកសារណាមួយយោងអង្គហេតុសម្ងាត់ ដែលកំពុងត្រូវបានស៊ើបអង្កេតក្នុងរឿងក្តី ០០៣ ឡើយ ហើយក៏គ្មានបញ្ហាចោទណាទាក់ទងនឹងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ដែលសាធារណជនមិនបានដឹងដែរ។ សាធារណជនគួរទទួលបានព័ត៌មានអំពីសំណើរបស់មេធាវីការពារក្តី ជាពិសេស នៅពេលពិចារណាពីការរិះគន់ អ.វ.ត.ក. ជាសាធារណៈថា ជាស្ថាប័នទទួលរងការជ្រៀតជ្រែកខាងនយោបាយ ទាក់ទងនឹងរឿងក្តី ០០៣ និង រឿងក្តី ០០៤[23]។ ដូចដែលអង្គការសង្គមយុត្តិធម៌សេរីបានកត់សម្គាល់ថា៖

> ការជ្រៀតជ្រែកជាក់ស្តែង នៅតែបន្តពីសំណាក់រដ្ឋាភិបាលទៅលើការវិវត្តនៃរឿងក្តី ០០៣ និង រឿងក្តី ០០៤ ជាពិសេស នៅចំពោះមុខនៃការឆ្លើយតបដែលមានការយឺតយ៉ាវ និង មិនសមរម្យពី អ.ស.ប. និង មន្ត្រីអន្តរជាតិនៃតុលាការ បង្កឲ្យមានផលប៉ះពាល់ជាបន្តដល់កេរដំណែល និង ធម្មនុញ្ញភាពនៃតុលាការទាំងមូល រហូតដល់ក្រោយរឿងក្តី ០០៣ និង រឿងក្តី ០០៤។ បញ្ហានេះនាំឲ្យមានការចំអកឡកឡឺយ និង ការមិនទុកចិត្តទាល់តែសោះទៅលើស្ថាប័ននេះ[24]។

---

[23] Heather Ryan និង Laura McGre អង្គការយុត្តិធម៌សង្គមសេរី *ការបំពេញការងារ និង ទស្សនទាន៖ ឥទ្ធិពលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* (Performance and Perception: The Impact of the Extraordinary Chamberes in the Courts of Cambodia) ទំព័រ ២៨ ដល់ ២៩ (មូលនិធិសង្គមសេរី ឆ្នាំ ២០១៦) ("របាយការណ៍ OSJI ឆ្នាំ ២០១៦")។ *សូមមើលផងដែរ* Alex Batesmith *បញ្ហាប្រឈមនៃយុត្តិធម៌អន្តរកាលដែលមេធាវីកំពុងតែប្រឈមក្នុងប្រទេសកម្ពុជា* (Transitional Justice Challenges Facing Lawyers in Cambodia) គម្រោងមេធាវី ការទំនាស់ និង អន្តរកាល ក្រុមប្រឹក្សាស្រាវជ្រាវសេដ្ឋកិច្ច និង សង្គម ខែមិថុនា ឆ្នាំ ២០១៥ ទំព័រ ៧៖ "មានគ្រោះថ្នាក់ពិតប្រាកដដែលថា ការរិះគន់ចំពោះ អ.វ.ត.ក. ក្នុងការខកខានមិនបានបំពេញដូចការរំពឹងទុកខាងយុត្តិធម៌ អាចនាំឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ទំនុកចិត្តសាធារណៈ មិនត្រឹមតែទៅលើតុលាការផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទៅលើសមត្ថភាពនៃការស្វែងរកយុត្តិធម៌នៅកម្រិតអន្តរជាតិជារួមសម្រាប់បំពេញចិត្តរបស់ប្រជាជន។ ចំណុចនេះនាំឲ្យមានការបារម្ភជាពិសេស នៅពេលនីតិរដ្ឋកំពុងស្ថិតក្រោមការគម្រាមកំហែងខ្លាំង ដូចជាករណីនៅក្នុងប្រទេសកម្ពុជា"។

[24] របាយការណ៍ OSJI ឆ្នាំ ២០១៦ ទំព័រ ២៨ ដល់ទំព័រ ២៩។

ការប្រកាន់យកតម្លាភាពពាក់ព័ន្ធនឹងផ្នែកដែលមិនមែនជាអង្គហេតុ ក្នុងកិច្ចស៊ើបអង្កេតរឿងក្តី ០០៣ ធ្វើឱ្យរូបភាពរបស់ អ.វ.ត.ក. មានភាពល្អប្រសើរ ក្នុងនាមជាតុលាការមួយដែលការពារ និង លើកកម្ពស់នីតិរដ្ឋក្នុងប្រទេសកម្ពុជា។

*លិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិផ្ញើជូន អ.ស.ប. ស្នើសុំឯកសារបណ្ណសារសម្ងាត់បំផុត*

១៦. បន្ទាប់ពីទទួលបានសំណើរបស់លោក មាស មុត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសរសេរលិខិតទៅកាន់ការិយាល័យទទួលបន្ទុកផ្នែកច្បាប់នៃ អ.ស.ប. ស្នើសុំឯកសារសម្ងាត់បំផុតទាក់ទងនឹងប្រវត្តិនៃកិច្ចចរចាបង្កើត អ.វ.ត.ក.[25]។ លិខិតនេះទាក់ទងនឹងឯកសារមួយចំនួនក្នុងសំណុំរឿងដូចជា សំណើរបស់លោក មាស មុត សុំសម្ភារៈឯកសារ និង ចម្លើយរបស់អង្គការ អ.ស.ប. តបទៅនឹងលិខិតនេះ[26] ប៉ុន្តែលិខិតនេះផ្ទាល់មិនត្រូវបានដាក់ទៅក្នុងសំណុំរឿងឡើយ ហើយក៏មិនទាន់មានសម្រាប់ភាគីដែរ។ លិខិតនេះ គឺជាការប្រាស្រ័យទាក់ទងរវាងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និង អ.ស.ប. ដែលត្រូវបានធ្វើឡើងដោយសារសំណើរបស់លោក មាស មុត ស្នើសុំសម្ភារៈឯកសារ។ លិខិតនេះមានជាប់ទាក់ទិនផ្នែកបរិបទទៅនឹងបញ្ហាដែលបានលើកឡើងក្នុងសំណើនេះ។ មេធាវីការពារក្តីស្នើឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដាក់លិខិតនេះភ្លាមទៅក្នុងសំណុំរឿង។ លិខិតនេះទៀតសោតក៏គួរតែដាក់បង្ហាញជាសាធារណៈផងដែរ។

១៧. គ្មានភាគី ឬ អង្គភាពនៃ អ.វ.ត.ក. នឹងរងព្យសនកម្មឡើយ ប្រសិនបើលិខិតនេះត្រូវបានធ្វើចំណាត់ប្រភេទជាឯកសារសាធារណៈនោះ។ សន្មតថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានបញ្ចូលទៅក្នុងលិខិតនេះនូវព័ត៌មានសម្ងាត់ណាមួយអំពីអង្គហេតុ ដែលកំពុងត្រូវបានស៊ើបអង្កេតក្នុងរឿងក្តី ០០៣។ ប្រសិនបើលិខិតនោះពិតជាមានព័ត៌មានសម្ងាត់បែបនេះណាមួយនោះ មេធាវីការពារក្តីស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដាក់បង្ហាញជាសាធារណៈនូវសំណៅកោសលុបនៃលិខិតនេះទៅក្នុងសំណុំរឿង អនុលោមតាមមាត្រា ៩.២ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទឯកសារ។ ការដាក់លិខិតនេះទៅក្នុងសំណុំរឿង និង ដាក់លិខិតនេះជាសាធារណៈ

---

[25] សេចក្តីជូនដំណឹងអំពីការព្យាយាមមិនបានសម្រេច ដើម្បីទទួលបានឯកសារបណ្ណសារសម្ងាត់បំផុតរបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D181/1 កថាខណ្ឌ ៥។

[26] *សូមមើល ឧទាហរណ៍* ឯកសារ D170, D170.2, D181/1, D181/1.1, D181/1.2, D181/1.3 និង ឯកសារ D181/1.4។

ធានាឱ្យមានតម្លាភាពក្នុងកិច្ចដំណើរការនីតិវិធី។ សាធារណជនក៏ទទួលបានព័ត៌មានផងដែរអំពីកិច្ចខិតខំប្រឹងប្រែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការស៊ើបអង្កេតស៊ីជម្រៅលើបញ្ហាដែលត្រូវចេញសេចក្តីសម្រេច៖ យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ក្នុងការស៊ើបអង្កេត និង ការចោទប្រកាន់ជនសង្ស័យ ជនត្រូវចោទ និង ជនជាប់ចោទ។

***<u>ចម្លើយរបស់ អ.ស.ប. តបទៅនឹងលិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ឯកសារ D181/1.1, D181/1.2, D181/1.3 និង ឯកសារ D181/1.4)</u>***

១៨. នៅក្នុងឯកសារ **D181/1.1** អគ្គលេខាធិការរងនៃ អ.ស.ប. បានផ្តល់ដំណឹងអំពីការបដិសេធរបស់ អ.ស.ប. ក្នុងការបង្ហាញសម្ភារៈឯកសារសម្ងាត់បំផុតដែលបានស្នើ ទៅសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ យោងតាមអគ្គលេខាធិការរងរបស់ អ.ស.ប. អគ្គលេខាធិការនៃ អ.ស.ប. មានឆន្ទានុសិទ្ធិផ្តាច់មុខក្នុងការបញ្ចេញឯកសាររបស់ អ.ស.ប. និង ពិនិត្យមើលសំណើតាមករណីនីមួយៗ ដើម្បីវាយតម្លៃលើភាពរសើបនៃឯកសារទាំងនោះ[27]។ អគ្គលេខាធិការរងនៃ អ.ស.ប. បានបង្ហាញថា ឯកសារសម្ងាត់បំផុតភាគច្រើនគឺជា "ឯកសារផ្ទៃក្នុងអន្តរការិយាល័យ ឬ ឯកសារផ្ទៃក្នុងពីការិយាល័យមួយទៅការិយាល័យមួយទៀត រួមទាំងសេចក្តីព្រាងឯកសារ [ដែល] ការបង្ហាញអាចប៉ះពាល់ដល់ដំណើរការនៃការធ្វើសេចក្តីសម្រេចដោយសេរី និង ឯករាជ្យរបស់ស្ថាប័ននេះ"[28]។ តាមរយៈលិខិតរបស់គាត់ អគ្គលេខាធិការរងនៃ អ.ស.ប. បានបញ្ចូលនូវឯកសារ ដែល អ.ស.ប. បានកំណត់ថា អាចត្រូវបានបង្ហាញដោយគ្មានការរឹតត្បិត[29]។ ឯកសារ **D181/1.2** ដែលជាសេចក្តីសម្រេចរបស់មហាសន្និបាត អ.ស.ប. ទាក់ទងនឹងប្រទេសកម្ពុជា ត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័ររបស់ជំនួយ អ.ស.ប. ដល់សាលាក្តីខ្មែរក្រហម (United Nations Assistance to the Khmer Rouge Trials)[30]។ ឯកសារ **D181/1.3** ដែលជារបាយការណ៍ស្តីពីប្រទេសកម្ពុជា ដែលរៀបចំឡើងដោយអគ្គលេខាធិការ អ.ស.ប. ត្រូវបានផ្សព្វផ្សាយជាសាធារណៈ

---

[27] ឯកសារ **D181/1.1** ទំព័រ ១។

[28] ឯកសារ **D181/1.1** ទំព័រ ២ ដែលយោងផ្នែក (ឃ) នៃសេចក្តីប្រកាសនៃអគ្គលេខាធិការ អ.ស.ប. ចុះថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០០៧ ស្តីពីភាពរសើប ចំណាត់ថ្នាក់ និង ការចាត់ចែងព័ត៌មាន (Information Sensitivity, Classification and Handling) (ST/SGB/2007/6)។

[29] *សូមមើល* ឯកសារ **D181/1.1** ទំព័រ ២។

[30] *សូមមើល* http://www.unakrt-online.org/sites/default/files/documents/A-RES-52-135%281%29.pdf។

នៅក្នុងបណ្ណាល័យឌីជីតថលតាមប្រព័ន្ធអ៊ីនធើណែតរបស់ អ.ស.ប.[31]។ ឯកសារ **D181/1.4** មានប្រតិចារឹកនៃសន្និសីទសារព័ត៌មានសាធារណៈដែលបានធ្វើឡើងក្នុងប្រទេសកម្ពុជា ដោយអតីតសមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិក លោក John Kerry និង អត្ថបទសារព័ត៌មានទាក់ទងនឹងកិច្ចចរចារវាង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា។ ឯកសារទាំងនេះគួរត្រូវបានដាក់បង្ហាញជាសាធារណៈ។

១៩. គ្មានភាគី ឬ អង្គភាពនៃ អ.វ.ត.ក. នឹងរងព្យសនកម្មឡើយ ប្រសិនបើឯកសារ **D181/1.1**, **D181/1.2**, **D181/1.3** និង **D181/1.4** ត្រូវបានធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈនោះ។ មូលហេតុរបស់ អ.ស.ប. ក្នុងការបដិសេធមិនផ្តល់ឯកសារសម្ងាត់បំផុត គឺមិនអាចទទួលយកបាន និង ឥតខ្លឹមសារ។ កិច្ចចរចារវាង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា បានបញ្ចប់នៅឆ្នាំ ២០០៣ ដែលមានរយៈពេលជាង ១០ ឆ្នាំកន្លងទៅហើយ។ វាមិនទំនងទាល់តែសោះដែលឯកសារមានអាយុច្រើនជាង ១០ ឆ្នាំទៅហើយនោះ អាចធ្វើឱ្យប៉ះពាល់ ឬ ធ្វើឱ្យអន្តរាយដល់លទ្ធភាពបច្ចុប្បន្នរបស់ អ.ស.ប. ក្នុងការធ្វើសេចក្តីសម្រេចដោយសេរី និង ឯករាជ្យនោះ។ ទោះជាយ៉ាងនេះក្តី ទាំងលិខិតរបស់ អ.ស.ប. ទាំងឯកសារភ្ជាប់មកជាមួយនឹងលិខិតនេះ ពុំមានយោងខ្លឹមសារនៃឯកសារសម្ងាត់បំផុតណាមួយ ឬ អង្គហេតុសម្ងាត់ណាមួយ ដែលកំពុងត្រូវបានស៊ើបអង្កេតក្នុងរឿងក្តី ០០៣ នោះទេ។ ឯកសារទាំងនេះគួរត្រូវបានដាក់បង្ហាញជាសាធារណៈ ដើម្បីឱ្យសាធារណជនក្នុងប្រទេសកម្ពុជា និង សហគមន៍អន្តរជាតិបានដឹងពីលក្ខខណ្ឌចង្អៀតដែលដាក់ដោយ អ.ស.ប. ខ្លួនឯងលើកិច្ចសហការរបស់ខ្លួនជាមួយនឹង អ.វ.ត.ក.។ ការរក្សាឯកសារទាំងនេះជាឯកសារសម្ងាត់កាន់តែបន្ថែមការយល់ឃើញជាសាធារណៈដែលថា អ.ស.ប. សហការពេញលេញជាមួយ និង គាំទ្រដល់ អ.វ.ត.ក. នៅពេលដែលការពិត គឺផ្ទុយពីនេះ។

*__សេចក្តីជូនដំណឹងអំពីការព្យាយាមមិនបានសម្រេច ដើម្បីទទួលបានឯកសារបណ្ណសារសម្ងាត់បំផុតរបស់អង្គការសហប្រជាជាតិ__* __(D181/1)__

២០. នៅក្នុងឯកសារ **D181/1** សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានជូនដំណឹងដល់ភាគីថា អ.ស.ប. បានបដិសេធមិនផ្តល់ឱ្យសម្ភារៈឯកសារសម្ងាត់បំផុត ដែលមានរៀបរាប់ក្នុងឯកសារ **D170.2**។ គាត់បានបង្ហាញថា ដោយគ្មានការអនុញ្ញាតពី អ.ស.ប. គាត់មិនអាចទទួលបានឯកសារនេះទេ

[31] *សូមមើល* http://repository.un.org/handle/11176/221321។

ប៉ុន្តែ គាត់នឹងព្យាយាម ដើម្បីទទួលបានសម្ភារៈឯកសារដែលមិនសម្ងាត់ពីបណ្ណសារដ្ឋានរបស់ អ.ស.ប.[32]។ សេចក្តីជូនដំណឹងនេះគួរត្រូវបានដាក់បង្ហាញជាសាធារណៈ។

២១. គ្មានភាគី ឬ អង្គភាពនៃ អ.វ.ត.ក. នឹងរងព្យសនកម្មឡើយ ប្រសិនបើឯកសារ **D181/1** ត្រូវបានធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈនោះ។ សេចក្តីជូនដំណឹងនេះមិនយោងព័ត៌មានសម្ងាត់ណាមួយ ដែលផ្តល់ដោយ អ.ស.ប. ឬ អង្គហេតុសម្ងាត់ណាមួយដែលកំពុងត្រូវបានស៊ើបអង្កេតក្នុងរឿងក្តី ០០៣ ឡើយ។ សេចក្តីជូនដំណឹងនេះត្រូវបានធ្វើឡើង ដើម្បីផ្តល់ព័ត៌មានដល់ភាគីអំពីស្ថានភាពនៃកិច្ចខិតខំប្រឹងប្រែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការយកសម្ភារៈឯកសារដែលស្នើដោយលោក មាស មុត ក្នុងឯកសារ **D170**។ ជាផលប្រយោជន៍នៃតម្លាភាព និងយុត្តិធម៌ ដែលសាធារណជនបានដឹងពីការបដិសេធរបស់ អ.ស.ប. មិនអនុញ្ញាតឲ្យចូលពិនិត្យមើលពេញលេញនូវប្រវត្តិចរចារវាង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា។ ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេច ពិចារណាលើប្រវត្តិពេញលេញនៃកិច្ចចរចាបង្កើត អ.វ.ត.ក. "ច្បាស់ណាស់ អាចជួយ" សហចៅក្រមស៊ើបអង្កេតកំណត់ពីចេតនារបស់អ្នករៀបចំសេចក្តីព្រាងទាក់ទងនឹងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក.[33]។ អ.ស.ប. គាំទ្រ និង តស៊ូមតិជាសាធារណៈ ដើម្បីឲ្យ អ.វ.ត.ក. បន្តការស៊ើបអង្កេត និង ការចោទប្រកាន់[34] ប៉ុន្តែមិនបានស្ទាក់ស្ទើរក្នុងការបដិសេធកិច្ចខំប្រឹងប្រែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការស៊ើបអង្កេតឲ្យបានពេញលេញលើកិច្ចចរចា នៅពេលដែលខ្លួនចាត់ទុកថា ផលប្រយោជន៍របស់ អ.ស.ប. ស្ថិតក្នុងហានិភ័យ។ ការបន្តរក្សាសេចក្តីជូនដំណឹងនេះជាឯកសារសម្ងាត់ មិនបានផ្តល់ផលប្រយោជន៍ដល់អ្នកណាម្នាក់ឡើយ។ វាគ្រាន់តែជំរុញឲ្យមានទម្លាប់អនុវត្តអាក្រក់បំផុត ដែលសង្កេតឃើញដោយសហគមន៍អន្តរជាតិ៖ ការធ្វើសេចក្តីសម្រេចតាមឆន្ទៈនយោបាយ និង ការជ្រៀតជ្រែកក្នុងរឿងក្តី ០០៣[35]។

---

[32] សេចក្តីជូនដំណឹងអំពីការព្យាយាមមិនបានសម្រេច ដើម្បីទទួលបានឯកសារបណ្ណសារសម្ងាត់បំផុតរបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារ D181/1 កថាខណ្ឌ ៦។

[33] ដីកាសម្រេចរួមលើសំណើរបស់ មាស មុត ស្តីពីយុត្តាធិការបុគ្គល ចុះថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D181 កថាខណ្ឌ ៣២។

[34] *សូមមើល ខាងលើ* កំណត់សម្គាល់លេខ ២២។

[35] របាយការណ៍របស់ OSJI ឆ្នាំ ២០១៦ កំណត់សម្គាល់លេខ ៧៩ ដែលកត់សម្គាល់ពីសេចក្តីថ្លែងការណ៍របស់ខ្លួនម្តងហើយម្តងទៀតអំពីការធ្វើសេចក្តីសម្រេចតាមឆន្ទៈនយោបាយក្នុងរឿងក្តី ០០៣ និង រឿងក្តី ០០៤។ ដូចខាងលើ ទំព័រ ២៨ ដែលកត់សម្គាល់ថា ការបន្តជ្រៀតជ្រែកជាក់ស្តែងរបស់រដ្ឋាភិបាល ក្នុងរឿងក្តី ០០៣ និង រឿងក្តី ០០៤ និង "ចម្លើយដែលមានភាព

សហចៅក្រមស៊ើបអង្កេតអន្តរជាតិគួរអនុវត្តទម្លាប់ដែលមានតម្លាភាព ដូចដែលជំរុញដោយមេធាវីការពារក្តី។ តម្លាភាពនឹងជួយបំភ្លឺទាំងលើកិច្ចដំណើរការនីតិវិធីក្នុងរឿងក្តី ០០៣ និង លើឧបសគ្គរាំងដល់កិច្ចដំណើរការនីតិវិធី ដែលបង្កឡើងដោយ អ.ស.ប. ដែលជាស្ថាប័នជំរុញឱ្យបន្តកិច្ចស៊ើបអង្កេតជាសាធារណៈ ខណៈដែលក្នុងផ្លូវឯកជន បដិសេធមិនផ្តល់មធ្យោបាយ ដែលអាចឱ្យកិច្ចស៊ើបអង្កេតទាំងនោះបន្តទៅមុខបាន។

## IV. ដំណោះស្រាយដែលស្នើសុំ

**អាស្រ័យហេតុនេះ** ផ្អែកតាមសំអាងហេតុដែលបានរៀបរាប់ខាងលើ មេធាវីការពារក្តីគោរពស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតមេត្តា៖

**ក. ធ្វើចំណាត់ប្រភេទឡើងវិញ** ជាឯកសារសាធារណៈចំពោះឯកសារ D170, D170.2, D181/1, D181/1.1, D181/1.2, D181/1.3 និង ឯកសារ D181/1.4 ។ និង

**ខ. ដាក់** ក្នុងសំណុំរឿង និង **ធ្វើចំណាត់ប្រភេទ** ជាឯកសារសាធារណៈចំពោះលិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិផ្ញើជូន អ.ស.ប. ស្នើសុំឯកសារបណ្ណសារសម្ងាត់បំផុតរបស់ អ.ស.ប.។

សូមលោកចៅក្រមមេត្តាទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី **១២** ខែ**ឧសភា** ឆ្នាំ **២០១៦**
សហមេធាវីការពារក្តីលោក មាស មុត

| | |
|---|---|
| អាង ឧត្តម | Michael G. KARNAVAS |

យ៉ឹតយ៉ាវ និង មិនសមស្រប" ពី អ.ស.ប. និង មន្ត្រីអន្តរជាតិនៅ អ.វ.ត.ក.។